YUNNAN DAILY PRESS GROUP
云南日报报业集团
No.165

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7724 ថ្ងៃសុក្រ ទី 31 ខែ សីហា ឆ្នាំ 2018

## ខេត្តយូនណាន និងប្រទេសកម្ពុជាពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយគ្នា

ឆ្នាំនេះជាខួបលើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសចិននិងកម្ពុជា ។ ក្នុងនាមជាខេត្តមួយដែលស្ថិតនៅជិតនឹងប្រទេសកម្ពុជាជាងគេក្នុងប្រទេសចិនយូនណានខិតខំប្រឹងប្រែងដើម្បីបង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសកម្ពុជានិងបានទទួលសមិទ្ធផលជាក់ស្តែងក្នុងការអនុវត្តគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅប្រទេសកម្ពុជា ។

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨ អ្នកសារព័ត៌មានបានជួបជាមួយលោកលី សាវយាន់ អគ្គនាយករងផ្នែកវិស្វកម្មអន្តរជាតិនៃក្រុមហ៊ុនសាងសង់និងវិនិយោគខេត្តយូនណានគ្រុប ។ លោកបានធ្វើការនៅប្រទេសកម្ពុជា១០ឆ្នាំហើយទើបត្រឡប់មកប្រទេសចិនវិញនៅ ៣-៤ខែមុន ។

នៅឆ្នាំ២០០៩ ក្រុមហ៊ុនបានចាត់តែងឱ្យលោកទៅធ្វើការនៅប្រទេសកម្ពុជា ។ ក្នុងអំឡុងពេល១០ឆ្នាំ នោះក្រុមហ៊ុនសាងសង់ និងវិនិយោគខេត្តយូនណានគ្រុបបានទទួលបន្ទុកអនុវត្តន៍គម្រោងសំខាន់មួយចំនួនធំនៅប្រទេសកម្ពុជា ដូចជាអគារការិយាល័យនៃរាជរដ្ឋាភិបាលកម្ពុជាអគារការិយាល័យផ្តល់ទិដ្ឋាការនិងសេវាកម្មគ្រប់គ្រងនៃស្ថានទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជាជាដើម។ ក្នុងនាមជាអ្នកទទួលខុសត្រូវនៃក្រុមហ៊ុនលោកបានចូលរួមអនុវត្តន៍គម្រោងទាំងនេះនៅប្រទេសកម្ពុជា។

លោកបានបញ្ជាក់ថា គម្រោងដែលជួបនឹងការលំបាកច្រើនជាងគេ គឺសាងសង់បន្ទប់ក្រោមដីនៅលើកោះពេជ្រ ។ គម្រោងនេះមានទីតាំងស្ថិតនៅជាប់នឹងទន្លេមេគង្គ ។ កាលនោះកម្ពុជាបានកើតមានទឹកជំនន់ដ៏កម្រឃើញដែលបានធ្វើឱ្យទន្លេមេគង្គឡើងទឹកខ្ពស់ ។ ទឹកទន្លេបានហូរចូលក្នុងការដ្ឋានសាងសង់ ។ គេបានប្រើវិធីច្រើនតែមិនអាចដោះស្រាយបញ្ហានេះ ។ ក្រោយមកយើងបានអញ្ជើញអ្នកជំនាញការពីប្រទេសចិនទៅធ្វើការសិក្សាស្រាវជ្រាវយ៉ាងស៊ីជម្រៅទើបសម្រេចបាននូវគម្រោងនេះដោយជោគជ័យ ។

ក្រុមហ៊ុនសាងសង់និងវិនិយោគខេត្តយូណាន គ្រុបបានទទួលសមិទ្ធផលជាក់ស្តែងដ៏ច្រើននៅប្រទេសកម្ពុជា ។ នៅឆ្នាំ ២០១៨ក្រុមហ៊ុនបានសាងសង់អគារការិយាល័យនៃរាជរដ្ឋាភិបាលកម្ពុជា។ នៅឆ្នាំ២០១៧ ក្រុមហ៊ុនបានចុះកិច្ចសន្យាដែលមានទំហំពាណិជ្ជកម្ម ១.១២៤ លានយ័នប្រាក់ចិន ។ គម្រោងដែលអនុវត្តន៍ដោយក្រុមហ៊ុនមានគុណភាពស្របតាមស្តង់ដារ១០០ភាគរយ និងបានទទួលការវាយតម្លៃខ្ពស់ពីភាគីទាំងពីរចិននិងកម្ពុជា ។

លោកលី ហៃជីន អនុប្រធានក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនសាងសង់និងវិនិយោគខេត្តយូនណាន គ្រុបបានធ្វើបទឧទ្ទេសនាមថា ក្រុមហ៊ុនបានចូលរួមធ្វើវិនិយោគនិងសាងសង់ព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាបថ្មីនៅប្រទេសកម្ពុជា ។ សព្វថ្ងៃការងារត្រៀមបម្រុងកំពុងដំណើរការយ៉ាងរលូន ។ ក្រុមហ៊ុននឹងខិតខំប្រឹងប្រែងដើម្បីធានាឱ្យគម្រោងនេះបើកការដ្ឋានសាងសង់ទាំងស្រុងនៅឆ្នាំនេះ ហើយបញ្ចប់ការសាងសង់តាមពេលកំណត់ ។ មិនតែប៉ុណ្ណោះក្រុមហ៊ុននឹងខិតខំជំរុញឱ្យគម្រោងសាងសង់ព្រលានយន្តហោះថ្មីនេះដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍខ្សែសង្វាក់ផលិតកម្មពាក់ព័ន្ធ ។៕

**ដោយអ៊ូ ភីង**

## ការប្រកួតរត់ម៉ារ៉ាតុងអន្តរជាតិក្រុងគុនមីង ឆ្នាំ២០១៨ នឹងប្រារព្ធនៅថ្ងៃទី២ ខែធ្នូ



*ការប្រកួតរត់ម៉ារ៉ាតុងអន្តរជាតិក្រុងគុនមីងឆ្នាំ២០១៨ បានក្លាយជា ការប្រកួតដែលកំពុងតែមានប្រជាប្រិយភាព នៅក្នុងប្រទេសចិន និង ពិភពលោក ( រូបថតដោយ Zhang Tong )*

ពេលថ្មីៗនេះ សន្និសីទសារព័ត៌មានអំពី "ក្រុមហ៊ុនផលិតអំបិលខេត្តយូនណាន:ការប្រកួតរត់ម៉ារ៉ាតុងអន្តរជាតិក្រុងគុនមីងឆ្នាំ២០១៨ នៃអង្គការសហប្រតិបត្តិការសៀងហៃ" បានប្រារព្ធនៅក្រុងគុនមីងនៃខេត្តយូនណាន។ តាមដំណឹងពីសន្និសីទសារព័ត៌មាននេះបានឱ្យដឹងថា ការប្រកួតរត់ម៉ារ៉ាតុងអន្តរជាតិក្រុងគុនមីងឆ្នាំ២០១៨ នៃអង្គការសហប្រតិបត្តិការសៀងហៃនេះនឹងបើកការប្រកួតនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៨ ។

គួរបញ្ជាក់ថា ការប្រកួតរត់ម៉ារ៉ាតុងអន្តរជាតិនេះ មានទ្រង់ទ្រាយកាន់តែធំជាងឆ្នាំមុនៗ។ ចំនួននៃអ្នកចូលរួមបានកើនឡើងពី១,៦ម៉ឺននាក់នៅឆ្នាំ២០១៦ និងឆ្នាំ២០១៧ដល់២ម៉ឺននាក់នៅឆ្នាំ២០១៨។ ការប្រកួតកីឡាដែលរៀបចំដោយលេខាធិការដ្ឋាននៃអង្គការសហប្រតិបត្តិការសៀងហៃនិងសាលារដ្ឋបាលប្រជាជនខេត្តយូនណាននេះ មានឥទ្ធិពលកាន់តែខ្លាំងឡើងៗក្នុងបណ្តាប្រទេសជាសមាជិកនៃអង្គការសហប្រតិបត្តិការសៀងហៃ និងបានក្លាយទៅជាវេទិកាដ៏សំខាន់សម្រាប់ជំរុញការផ្លាស់ប្តូរផ្នែកវប្បធម៌ក្នុងក្របខ័ណ្ឌអង្គការសហប្រតិបត្តិការសៀងហៃ។៕

**ដោយយ៉ាង ហ្វុតុង**

## ផ្សិតព្រៃក្លាយជាវត្ថុស័ក្តិសិទ្ធិសម្រាប់ស្វែងរកជីវភាពធូរធារ



*ទីផ្សារផ្សិតព្រៃ Shuimuhua នៅគុនមីង គឺជាទីផ្សារសំខាន់មួយ ដែលសម្បូរ ផលិតផលផ្សិតព្រៃជាច្រើនប្រភេទ (រូបថតដោយ Li Qiuming )*

នៅរដូវក្តៅផ្សិតព្រៃនៅខេត្តយូនណាន ចាប់ផ្តើមត្រូវគេដាក់លក់តាម ទីផ្សារ ។ សព្វថ្ងៃផ្សិតព្រៃរបស់ខេត្តយូនណានបាននាំមកនូវមុខរបរមួយដែលមានទំហំពាណិជ្ជកម្មជាងមួយម៉ឺនលានយ័នហើយបានក្លាយទៅជាវត្ថុដ៏ស័ក្តិសិទ្ធិសម្រាប់កាត់បន្ថយភាពក្រីក្រនិងស្វែងរកជីវភាពធូរធារឱ្យប្រជាជនក្នុងតំបន់ភ្នំ ។

តាំងពីឆ្នាំ២០១៧ មក លោក ឈឺន ស្មៀវ ជូនបានម៉ៅព្រៃឈើលើភ្នំមួយកន្លែងដែលមានផ្ទៃក្រឡាជាង ៣០ ហិកតាក្នុងភូមិថាស៊ីយ៉ាន ស្រុកឈឺងជាំងក្រុងយូស៊ី ខេត្តយូនណាន ។ ទីនេះសម្បូរផ្សិតព្រៃ ។ គេអាចរកបានផ្សិតព្រៃគ្រប់ប្រភេទពីខែ ឧសភាដល់ខែតុលាជារៀងរាល់ឆ្នាំ ដូចជាផ្សិតឈឹងធូវ ផ្សិតកាន់ប៉ានិងផ្សិតនីវកាន់ជាដើម ។ រាល់ព្រឹក លោក ឈឺន ស្មៀវឈុងអាចរកបានផ្សិតព្រៃជាង២០គីឡូក្រាម ។ បើគិតតាមតម្លៃទីផ្សារគាត់អាចទទួលបានចំណូលជាង ១០ម៉ឺនយ័ននៅឆ្នាំនេះ ។

អ្នករកស៊ីដែលរកនិងលក់ផ្សិតព្រៃដូចឈឺន ស្មៀវឈុប មានចំនួនច្រើនក្នុងខេត្តយូនណាន ។ អ្នកខ្លះចូលទៅរកផ្សិតព្រៃក្នុងតំបន់ភ្នំតាមរដូវអ្នកខ្លះទៀតបានម៉ៅតំបន់ភ្នំដើម្បីរកស៊ីប្រកបរបរនេះ ។ តាមស្ថិតិពីសមាគមថែរក្សានិងអភិវឌ្ឍន៍ផ្សិតព្រៃខេត្តយូនណានបានឱ្យដឹងថា អ្នកប្រកបរបរដែលពាក់ព័ន្ធនឹងផ្សិតព្រៃនៅខេត្តយូនណានមានចំនួនប្រមាណ៣០ម៉ឺននាក់ ។

លោកលី ភៃគួយ ប្រធានសមាគមថែរក្សានិងអភិវឌ្ឍន៍ផ្សិតព្រៃខេត្តយូនណានបានបញ្ជាក់ថា ខេត្តយូនណានមានផ្សិតព្រៃ២.៧២៩ មុខដែលជាប់លំដាប់ទី១ ក្នុងប្រទេសចិន ។ សព្វថ្ងៃក្នុងទីផ្សារយូណានមានលក់ផ្សិតព្រៃជាង២៥០ប្រភេទ ក្នុងនោះមានផ្សិតព្រៃជា៩០ភាគរយ ជាផ្សិតដែលអាចហូបបាន ។៕ **(ស៊ីនហួចិន)**

## ការផ្លាស់ប្តូរនៃជោគវាសនារបស់ដំរីព្រៃឈ្មោះ "យ៉ាងនីវ " ប្រែក្លាយពី "ទារកដែលត្រូវគេបោះបង់ចោល "ទៅជា "តារាល្បីឈ្មោះ"

ល្ងាចថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ គេបានរកឃើញកូនដំរីមួយក្បាលដែលទើបកើតនៅភូមិកានឡានប៉ា ខណ្ឌស៊ឺម៉ៅក្រុងភូអឺ ។ កូនដំរីនេះបានត្រូវម្តាយវាបោះបង់ចោលហើយស្ទើរនឹងងាប់មើលទៅ ។

អ្នកការពារសត្វព្រៃបានជួយពិនិត្យសុខភាពរបស់វា ហើយបានរកឃើញថា វាមានបញ្ហាសុខភាពដ៏ច្រើនហើយមានការរលាកក្នុងពោះវា ។ កូនដំរីនេះបានត្រូវគេជូនទៅមជ្ឈមណ្ឌលបន្តពូជនិងសង្គ្រោះដំរីអាស៊ីក្នុងជ្រលងភ្នំដំរីព្រៃស៊ីសាំងប៉ានណាន ភ្លាមៗ ។ តាមរយៈការថែទាំយ៉ាងហ្មត់ចត់ពីអ្នកធ្វើការនៅទីនោះកូនដំរីនេះ មានសុខភាពកាន់តែល្អប្រសើរឡើង ។

ដោយសារកូនដំរីនេះកើតនៅឆ្នាំមមែ ហើយស៊ីទឹកដោះសត្វពពែតាំងពីតូចគេបានដាក់ឈ្មោះឱ្យវាថា "យ៉ាងនីវ" ដែលក្នុងភាសាចិនមានន័យថា "នាងពពែ" ។

អ្វីដែលបានធ្វើឱ្យយើងសប្បាយរីករាយនោះគឺ "យ៉ាងនីវ" បានធំធាត់ឡើងដោយមានសុខភាពល្អ។ ទម្ងន់របស់វាបានកើនឡើងពី៧៦គីឡូក្រាមដល់ជាង៧០០គីឡូក្រាម ។ វាត្រូវស៊ីទឹកដោះពពែ១៤គីឡូក្រាមក្នុងមួយ ថ្ងៃ។ ក្រៅពីនេះ វាត្រូវស៊ីរុក្ខជាតិព្រៃនិងផ្លែឈើច្រើនប្រភេទជារៀងរាល់ថ្ងៃ ដូចជាផ្លែចេក និងស្រកានាគជាដើម។

ឆ្នាំទៅ យ៉ាងនីវ បានសម្រេចនូវការហ្វឹកហាត់ក្នុងមជ្ឈមណ្ឌល ហើយបានត្រូវលែងចូលទៅក្នុងភ្នំព្រៃវិញ។ អ្នកថែទាំបានថតវីដេអូនៃទិដ្ឋភាព ដែលយ៉ាងនីវដើរចុះពីលើភ្នំហើយផ្សាយតាមបណ្តាញអ៊ីនធើណេតទាំងក្នុង និងក្រៅប្រទេសចិន។ សព្វថ្ងៃ យ៉ាងនីវ មានគណនីរបស់ខ្លួនតាមវេបសាយទំនាក់ទំនងសង្គម ហើយបានទទួលការចាប់អារម្មណ៍ពីគេ និងមានអ្នកគាំទ្រជាង ៣៨ម៉ឺននាក់ ។៕ **(ស៊ីនហួចិន)**



*ភ្ញៀវទេសចរកំពុងបញ្ចុក ចំណីដល់ដំរីព្រៃនៅមជ្ឈមណ្ឌលបន្តពូជ និងសង្គ្រោះដំរីអាស៊ីក្នុងជ្រលងភ្នំដំរីព្រៃស៊ីសាំងប៉ានណាន (រូបថត ដោយ Dai Zhenghua )*

## យូនណាននឹងបង្កើតមជ្ឈមណ្ឌលទេសចរណ៍បរទ្បានដោយខ្លួនឯងតភ្ជាប់ប្រទេសចិនជាមួយតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង

ខេត្តយូនណានសម្បូរធនធានធម្មជាតិ និងមានឧត្តមភាពពិសេសសម្រាប់អ្នកដែលចូលចិត្តធ្វើទេសចរដោយបរទ្បានខ្លួនឯង។ ខេត្តយូនណាននឹងបង្កើតខ្សែផ្លូវទេសចរណ៍ដ៏ល្អប្រណីត និងរៀបចំកន្លែងបោះជំរំសម្រាប់អ្នកធ្វើទេសចរដោយបរទ្បានខ្លួនឯងចំនួនជាង២០០កន្លែង ដើម្បីបង្កើតមជ្ឈមណ្ឌលទេសចរណ៍បរទ្បានខ្លួនឯងដែលតភ្ជាប់ប្រទេសចិនជាមួយតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង ។

អាស្រ័យលើគោលដៅនៃការបង្កើតខ្សែផ្លូវទេសចរណ៍ល្អប្រណីតចំនួន៣២ខ្សែ យូនណាននឹងខិតខំជំរុញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធផ្សេងៗ ដើម្បីផ្តល់សេវាកម្មសាធារណៈដូចជា ចំណតឈប់សម្រាកតាមផ្លូវវេទិកាគយគន់ទេសភាពស្អាត បន្ទប់ទឹកសាធារណៈ កន្លែងផ្តល់សេវាកម្មជួលទ្បាន និងមជ្ឈមណ្ឌលសង្គ្រោះបន្ទាន់ជាដើម។ ម្យ៉ាងទៀតយូនណាននឹងខិតខំកែលម្អលក្ខខណ្ឌនៃការធ្វើដំណើរសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិតាមរយៈការសាងសង់ និងជួសជុលផ្លូវតូចធំក្នុងខេត្ត ហើយនឹងរៀបចំកន្លែងបោះជំរំសម្រាប់អ្នកធ្វើទេសចរដោយបរទ្បានខ្លួនឯងចំនួនជាង២០០កន្លែង និងផ្តល់រថយន្តសម្រាប់ឱ្យអ្នកទេសចរជួលជាង១០ម៉ឺនគ្រឿងតាមទីផ្សារទេសចរណ៍ក្នុងខេត្ត។៕